ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ៣៣/១២-ដាយ យ៉ាំង
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ទូន ស៊ីផាន់**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ដាយ យ៉ាំង (ខេមបូឌា)**
អាសយដ្ឋាន ៖ ផ្លូវជាតិលេខ ៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៨៣០ ៩០១ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

១- លោក ព្រាប ឡេន ប្រធានរដ្ឋបាល
២- លោក ជូ ចាន់ស័ក ទីប្រឹក្សាក្រុមហ៊ុន

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖- **សហព័ន្ធសហជីពការងារកម្មករកម្ពុជា**
- **សហជីពការងារកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ដាយ យ៉ាំង**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ ៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៩២ ៨០០ ៩៦៣ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

| | |
|---|---|
| ១- លោក ឈិន សូនី | អនុប្រធានសហព័ន្ធសហជីពការងារកម្មករកម្ពុជា |
| ២- លោក ញ៉ែត វណ្ណី | ប្រធានសហជីពការងារកម្មកកម្ពុជាប្រចាំរោងចក្រដាយយ៉ាំង |
| ៣- លោក វ៉ី សុផាន់ណារ៉ា | អនុប្រធានសហជីពការងារកម្មករកម្ពុជា |
| ៤- លោក ស៊ូ ហេង | គណៈកម្មការសហជីព |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សុំឱ្យក្រុមហ៊ុនគោរពនូវសេចក្តីជូនដំណឹងរបស់ខ្លួន ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ត្រង់ចំណុចវិវាទទី ១, ២ និងទី៣ ។

២- សុំឱ្យក្រុមហ៊ុនគោរពនូវសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១។

៣- សុំឱ្យក្រុមហ៊ុនរៀបចំទឹកក្នុងបង្គន់ឱ្យបានគ្រប់គ្រាន់។

៤- ក្រុមហ៊ុនមិនត្រូវបង្ខិតបង្ខំកម្មករនិយោជិត ដែលដេរមិនបានគ្រប់ចំនួន។

៥- ក្រុមហ៊ុនមិនត្រូវធ្វើការគំគួនកម្មករនិយោជិត ដែលចូលរួមធ្វើកូដកម្មរយៈពេលកន្លងមក។

៦- ក្រុមហ៊ុនមិនត្រូវដាក់ធុងបាស់ ឬកាមេរ៉ាតាមផ្លូវចូលបន្ទប់ទឹកឡើយ។

៧- រាល់ពេលដែលមានបុណ្យផ្សេងៗ ក្រុមហ៊ុនត្រូវតែពិភាក្សាជាមួយសហជីព ដែលមានភាពតំណាងឱ្យបានដឹងផងពីរថ្ងៃមុន។

៨- សុំឱ្យក្រុមហ៊ុនរៀបចំបន្ទប់ប្រជុំសម្រាប់សហជីព ដែលមានភាពជាតំណាង។

៩- ក្រុមហ៊ុនត្រូវតែធ្វើការព្រមានប្រធានចិន ដែលប្រើពាក្យសំដីមិនសមរម្យមកលើកម្មករនិយោជិត។

១០- ក្រុមហ៊ុនមិនត្រូវធ្វើការគៀបសង្កត់មកលើកម្មករសាកល្បងឡើយ។

១១- នៅពេលកម្មការិនីធ្វើការបាន ៩ ខែ ហើយដាក់ពាក្យឈប់សម្រាកលំហែមាតុភាព សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលជូន។

១២- ក្រុមហ៊ុនមិនត្រូវធ្វើការផ្លាស់ប្តូរកម្មករនិយោជិតពីកន្លែងមួយទៅកន្លែងមួយឡើយ។

១៣- ក្រុមហ៊ុនបានសន្យាថា នឹងរក្សាប្រាក់ឈ្នួលដល់កម្មករនិយោជិត ដែលចូលរួមធ្វើកូដកម្មកន្លងមក ប៉ុន្តែពុំអនុវត្ត។

១៤- សុំឱ្យបុគ្គលិកការិយាល័យធ្វើការឱ្យបានច្បាស់លាស់។

១៥- សុំឱ្យមានពេទ្យប្រចាំរោងចក្រម្នាក់ទៀត។

១៦- សុំឱ្យក្រុមហ៊ុនបើកទ្វារទាំងអស់ពេលម៉ោងធ្វើការ។

THE ARBITRATION COUNCIL

១៧- ក្រុមហ៊ុនត្រូវព្រមានជនជាតិវៀតណាមឈ្មោះ ង៉ុក ពីបទថា កម្មករលួចម៉ូទ័រលក់ ។

១៨- សុំឱ្យក្រុមហ៊ុនដាក់អ្នកអនាម័យម្នាក់ទៀត ។

១៩- ក្រុមហ៊ុនមិនត្រូវដាក់កំណត់ target ឱ្យហួសកំលាំងកម្មករឡើយ ។

២០- ក្រុមហ៊ុនមិនត្រូវចាប់ទូរស័ព្ទដៃរបស់កម្មករគ្រាន់តែមើលម៉ោងឡើយ ។

២១- ក្រុមហ៊ុនធ្វើយ៉ាងណា ដើម្បីកុំឱ្យក្តៅនៅក្នុងរោងចក្រ ។

២២- ក្រុមហ៊ុនត្រូវប្រជុំប្រធានផ្នែក ប្រធានក្រុមក្នុងរយៈពេលមួយខែម្តង ។

២៣- ក្រុមហ៊ុនត្រូវមានការកោះប្រតិភូបុគ្គលិក ឬសហជីព ដែលមានភាពជាតំណាងបំផុតយ៉ាងយូរពីរខែម្តង ។

២៤- ក្រុមហ៊ុនត្រូវបើកប្រាក់បំណាច់ឆ្នាំជូនកម្មករ ដែលចូលធ្វើការបានមួយឆ្នាំ មិនត្រូវឱ្យហួសពីមួយខែទៀតឡើយ ។

២៥- ក្រុមហ៊ុនត្រូវព្រមានបុគ្គលិកឈ្មោះ រិន ដែលប្រើពាក្យសំដីមិនសមរម្យមកលើកម្មករ ។

២៦- ក្រុមហ៊ុនមិនត្រូវបើកថ្លៃបាយ ថ្លៃទឹកដោះគោ ថ្លៃធ្វើដំណើ និងប្រាក់បំណាច់ឆ្នាំ នៅថ្ងៃបុណ្យឡើយ ។

២៧- ក្រុមហ៊ុនត្រូវបើកប្រាក់ថ្លៃបាយមួយសប្តាហ៍ម្តង មិនត្រូវទុកដល់បីសប្តាហ៍ឡើយ ។

២៨- ក្រុមហ៊ុនត្រូវតែអនុវត្តនៅសេចក្តីជូនដំណឹងរបស់ខ្លួនអំពីការផ្តល់ប្រាក់ថ្លៃទឹកដោះគោ ធ្វើដំណើរ និងប្រាក់ថ្លៃបាយ សំរាប់ខែកញ្ញា ឆ្នាំ២០១១ ។

២៩- ក្រុមហ៊ុនត្រូវរៀបចំបន្ទប់សំរាប់ប្រជុំរបស់ប្រតិភូបុគ្គលិក ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិក ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានដកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១៨៥ កប/អក/វក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ ។

THE ARBITRATION COUNCIL

**សវនាការ និង សង្ខេបនីតិវិធី**

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១១ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ) ។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពការងារកម្មករកម្ពុជា ទាមទារសុំឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាសោះឡើយ លើការទាមទារចំនួន២៩ចំណុច។ ចំណុចមិនសះជាចំនួន២៩ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជា លេខ ១៨៥ កប/អក/វក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២។ បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ២៩ ចំណុចនេះ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១២ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ២៩ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ២៨ ចំណុច ដោយ១៨ចំណុច (ចំណុចទី២, ៤ ៥, ៦, ៨, ៩, ១១, ១២, ១៣, ១៤, ១៥, ១៩, ២០, ២២, ២៣, ២៥, ២៧ និង២៩) ភាគីកម្មករនិយោជិតបានដកការទាមទាររបស់ខ្លួន និង ០៩ ចំណុច (ចំណុចទី៣, ៧, ១០, ១៦, ១៧, ១៨, ២១, ២៤ និង ២៦) ភាគីវិវាទបានធ្វើការព្រមព្រៀងនឹងគ្នា។ ចំណែកចំណុចវិវាទទី២ និងទី២៨ ពុំទទួលបានការសះជានឹងគ្នាទេ ប៉ុន្តែ ដោយសារចំណុចវិវាទទាំងពីរនេះ គឺជាវិវាទតែមួយ ដូចនេះ ភាគីបានឯកភាពបញ្ចូលឱ្យទៅជាវិវាទតែមួយ ។

ដោយសារភាគីទាំងពីរជាហត្ថលេខីនៃអនុស្សរណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដូចនេះ ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបែងចែកសេចក្តីសម្រេចនៃចំណុចវិវាទជាពីរ គឺចំណុចវិវាទអំពីសិទ្ធិ និងចំណុចវិវាទអំពីប្រយោជន៍។ ភាគីទាំងពីរមិនមានសិទ្ធិប្តឹងជំទាស់លើសេចក្តី សម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើ ចំណុចវិវាទអំពីសិទ្ធិនោះទេ ព្រោះភាគីទាំងពីរបានព្រមព្រៀងគ្នា ឱ្យសេចក្តីសម្រេចនេះជាសេចក្តីសម្រេច ដែលជាប់កាតព្វកិច្ច តាមរយៈអនុស្សរណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ រួចហើយ។ ប៉ុន្តែ ភាគីអាចប្តឹងជំទាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីប្រយោជន៍ ប្រសិនបើភាគីជ្រើសរើសយកសេចក្តីសម្រេចមិនជាប់កាតព្វកិច្ចចំពោះវិវាទអំពីប្រយោជន៍។ ការប្តឹងជំទាស់របស់ភាគីទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីប្រយោជន៍ នឹងមិនបណ្តាលឱ្យប៉ះពាល់ទៅដល់កាតព្វកិច្ចក្នុងការ

អនុវត្តសេចក្តីសម្រេចដែលជាវិវាទអំពីសិទ្ធិទេ ដោយអនុលោមតាមស្មារតីនៃ អនុស្សារណៈនៃការ យោគយល់គ្នាខាងលើនោះ។ ក្នុងសំណុំរឿងនេះ ភាគីទាំងពីរជ្រើសរើសយកសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីផលប្រយោជន៍។

ភាគីក្នុងសំណុំរឿងនេះ ឯកភាពក្នុងការពន្យាពេលចេញសេចក្តីបង្គាប់រហូតដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០១២។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ដាយ យ៉ាំង គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសូមប្រគល់សិទ្ធិជូនលោក ព្រាប ឡេន និងលោក ជូ ចាន់ស៊ក លេខ ០០១/២០១២ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- សេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន ដាយ យ៉ាំង ស្តីពីការឧបត្ថម្ភប្រាក់មួយចំនួន ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១១។

២- សេចក្តីជូនដំណឹងស្តីពីកម្មការិនីណាមិនទាន់បានទទួលប្រាក់ថ្លៃទឹកដោះគោ ចំនួន ៣ ដុល្លារ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១។

៣- លិខិតជូនដំណឹងរបស់សហព័ន្ធសហជីពការងារកម្មករកម្ពុជា គោរពជូន លោកស្រីនាយិកាក្រុមហ៊ុន ដាយ យ៉ាំង ស្តីពីជូនដំណឹងអំពីសមាសភាពថ្នាក់ដឹកនាំថ្មី និងគណៈកម្មាធិការសហជីពការងារកម្មករកម្ពុជា នៃក្រុមហ៊ុន ដាយ យ៉ាំង លេខ ៨៧៦/២០១១ សសកកក ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១១។

៤- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពការងារកម្មករកម្ពុជា រោងចក្រកាត់ដេរ ដាយ យ៉ាំង បានចុះបញ្ជិកា លេខ ៥៤៦ សកបយ.អក ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៤។

៥- បង្កាន់ដៃទទួលសំណុំរឿងរបស់នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលពីសហជីពការងារកម្មករកម្ពុជា ស្តីពីសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីព ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២។

៦- លិខិតពឹងពាក់របស់ថ្នាក់ដឹកនាំសហជីពការងារកម្មករកម្ពុជា ប្រចាំនៅរោងចក្រ ដាយ យ៉ាំង គោរពជូនលោកប្រធានសហព័ន្ធសហជីពការងារកម្មករកម្ពុជា ស្តីពីស្នើសុំជួយចូលរួមអមដោះស្រាយអំពីលក្ខខណ្ឌការងារ និងបញ្ហាមួយចំនួន ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២។

៧- សេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៨៨/១១ និង ៨៩/១១-ដាយយ៉ាំង ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១។

៨- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុត របស់សហជីពការងារកម្មករកម្ពុជារោងចក្រកាត់ដេរ ដាយ យ៉ាំង លេខ ០២១/១០ ក.ប/វ.ប ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០។

៩- បញ្ជីរាយនាម និងស្នាមមេដៃសមាជិកសហជីពការងារកម្មករកម្ពុជានៃរោងចក្រ ដាយយ៉ាំង ដែលបានយល់ព្រមចូលជាសមាជិកសហជីពការងារកម្មករកម្ពុជា ហើយអនុញ្ញាតឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលចំនួន ១០០០ រៀល។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ដាយ យ៉ាំង លេខ ១៨៥ កប/អក/វក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ដាយយ៉ាំង ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១៩៣ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១៩៤ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២។

៣- ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា៖

- ក្រុមហ៊ុន ដាយ យ៉ាំង ខេមបូឌា គឺជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ មានជួលកម្មករនិយោជិតសរុបចំនួន ១០៥០ នាក់។

- សហជីពការងារកម្មករកម្ពុជា គឺជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ មានសមាជិកចំនួន ៥៦២ នាក់ តាមរយៈឯកសារ ដែលផ្តល់ដោយសហជីពការងារកម្មករកម្ពុជា។
- សហជីពការងារកម្មករកម្ពុជា គឺជាសហជីពដែលមានភាពជាតំណាងបំផុត។ វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុតនេះ នឹងផុតកំណត់នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១២។

ចំណុចវិវាទទី១ និងទី២៨ ៖ សុំឱ្យក្រុមហ៊ុនគោរពនូវសេចក្តីជូនដំណឹងរបស់ខ្លួន ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ត្រង់ចំណុចទី១ ទី២ និងទី៣

- នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិត និងនិយោជកបានឯកភាពគ្នាថា ចំណុចវិវាទទី១ និងទី២៨ គឺជាចំណុចវិវាទតែ១។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបញ្ចូលចំណុចវិវាទទាំងពីរ ជាចំណុចវិវាទតែមួយ។
- នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ក្រុមហ៊ុន ដាយ យ៉ាំង បានចេញសេចក្តីជូនដំណឹងមួយជូនដល់កម្មករនិយោជិត ដែលមានអត្ថន័យថា "ដោយយោងទៅតាមស្ថានការជាក់ស្តែងនៃការរស់នៅរបស់កម្មករ ដែលធ្វើការនៅក្នុងរោងចក្រ ដាយ យ៉ាំង សព្វថ្ងៃនេះ ហើយទំនិញនៅទីផ្សារក៏មានតំលៃខ្ពស់ ដូច្នេះ នាយកគ្រប់គ្រងរោងចក្រ ដាយ *យ៉ាំង បានឧបត្ថម្ភប្រាក់មួយចំនួន តាមចំណុចដូចខាងក្រោមនេះ ៖*

  *១- រោងចក្របានសំរេចបន្ថែមប្រាក់ថ្លៃទឹកដោះគោចំនួន ៣ ដុល្លារ ទៀតសម្រាប់ម្នាក់ៗ ជារៀងរាល់ខែ នៅលើប្រាក់ ៤ ដុល្លារ ដែលទទួលបានពីមុនរៀងរាល់ខែ សរុបទាំងអស់ ៧ដុល្លារក្នុង១ខែៗ។*

  *២- ចំពោះកម្មករធ្វើការចាប់ពីម៉ោង ៧៖០០ ព្រឹក ដល់ម៉ោង ៦៖០០ ល្ងាច ក្រុមហ៊ុនសំរេចផ្តល់ប្រាក់ក្នុងម្នាក់ៗចំនួន ១០០០ រៀល សំរាប់ថ្លៃក្នុងការធ្វើដំណើររបស់បងប្អូនកម្មករ។*

  *៣- កម្មករដែលធ្វើការនៅថ្ងៃបុណ្យ រោងចក្រឱ្យថ្លៃបាយចំនួន ១០០០ រៀល ដែលពីមុនមករោងចក្រមិនដែលឱ្យដល់កម្មករ។*

  *៤- ...។*

  *- សេចក្តីជូនដំណឹងនេះចាប់អនុវត្ត ពីខែកញ្ញា ឆ្នាំ២០១១ ខាងមុខនេះ តទៅ ..."*។

  តាមរយៈសេចក្តីជូនដំណឹងនេះ ភាគីនិយោជកពុំបានអនុវត្តផ្តល់ជូនកម្មករនិយោជិត ចាប់ពីខែកញ្ញា ឆ្នាំ២០១១ តទៅ ដូចដែលសេចក្តីជូនដំណឹងនេះបញ្ជាក់ទេ ប៉ុន្តែនិយោជកបានចាប់ផ្តើមផ្តល់ជូន ចាប់ពីខែតុលា ឆ្នាំ២០១១ មក។ នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ឱ្យនិយោជកសងនូវអត្ថប្រយោជន៍ តែក្នុងចំណុចទី១ និងទី២ នៃសេចក្តីជូនដំណឹងនេះតែប៉ុណ្ណោះ។ ពោល គឺសងនូវប្រាក់ថ្លៃទឹកដោះគោចំនួន ៣ ដុល្លារ ទៀត បន្ថែម សម្រាប់ម្នាក់ៗ ទៅលើប្រាក់ ៤ ដុល្លារអាមេរិក ដែលទទួលបានពីមុន និងទឹកប្រាក់ចំនួន ១០០០ រៀលក្នុងម្នាក់ៗ សំរាប់ថ្លៃធ្វើដំណើរ ចំពោះកម្មករនិយោជិតដែលធ្វើការ ចាប់ពីម៉ោង ៧ ៖ ០០ ព្រឹក ដល់ម៉ោង ៦ ៖ ០០ ល្ងាច។
- ភាគីនិយោជកបានលើកឡើងពីមូលហេតុ ដែលនិយោជក ពុំអាចអនុវត្តពីខែកញ្ញា ឆ្នាំ២០១១ គឺដោយសារនៅថ្ងៃទី១៦ ដល់ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១១ កម្មករនិយោជិតបានធ្វើកូដកម្មទូទាំងរោងចក្រ ដែលធ្វើឱ្យ

និយោជកខាតបង់ ដែលគិតជាទឹកប្រាក់មានចំនួនប្រហែល ២៥០ ០០០ (ម្ភៃប្រាំម៉ឺន) ដុល្លារអាមេរិក ពីការខកខានក្នុងការផ្ញើរទំនិញមួយចំនួនទៅអ្នកបញ្ជាទិញ ការប្តូរមធ្យោបាយផ្ញើរទំនិញតាមកប៉ាល់ មកតាមយន្តហោះ ដែលមានតម្លៃថ្លៃជាង និង ការផាកពិន័យពីការផ្ញើរទំនិញយឺតមួយចំនួនផងដែរ។

- ភាគីកម្មករនិយោជិតបានលើកឡើងថា ការធ្វើកូដកម្ម គឺជាការសម្រេចចិត្តរបស់កម្មករនិយោជិត ប៉ុន្តែ ក្នុងករណីនេះ និយោជកត្រូវតែគោរពទៅតាមសេចក្តីជូនដំណឹងរបស់ខ្លួន។ ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ចំពោះចំណុចទី១ នៃសេចក្តីជូនដំណឹងនេះ មានកម្មករនិយោជិតចំនួន ៣៥ នាក់ ជាសមាជិកសហជីព ដែលជាកម្មការិនីមានកូនតូចធ្វើការទាមទារ រីឯចំណុចទី២ គឺមានកម្មករនិយោជិតចំនួន ៥៦២ នាក់ ជាសមាជិកសហជីព ដែលបានផ្តិតមេដៃទាមទារ។

## ហេតុផលនៃសេចក្តីសម្រេចៈ

**ចំណុចវិវាទទី១ និងទី២៨ ៖ សុំឱ្យក្រុមហ៊ុនគោរពនូវសេចក្តីជូនដំណឹងរបស់ខ្លួន ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ត្រង់ចំណុចទី១ ទី២ និងទី៣**

មុននឹងពិចារណាចំណុចទាមទារទាំងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការទាមទារក្នុងចំណុចនេះជាវិវាទអំពីសិទ្ធិដែរ ឬទេ?

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទអំពីសិទ្ធិ គឺជាវិវាទទាក់ទងនឹងសិទ្ធិ ដែលមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង ឬអនុសញ្ញាមួយណាមួយចែងពីការទាមទារនោះ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល *លេខ០៥/១១-អ៊ុម វ៉េ (សាខាទី១) ហេតុផលចំណុចវិវាទទី១ និងទី៥, លេខ ១៣/១១-ហ្គូល កាំវីម៉ិច ហេតុផលចំណុចវិវាទទី១ និងទី២)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងខាងលើដែរ។

តាមរយៈការទាមទារនូវចំណុចវិវាទី១ និងទី២៨ នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំណុចវិវាទនេះ គឺជាវិវាទអំពីសិទ្ធិ ដោយហេតុថា ចំណុចវិវាទនេះទាក់ទងទៅនឹងសិទ្ធិ ដែលត្រូវទទួលបានដែលមានចែងនៅក្នុងសេចក្តីជូនដំណឹងរបស់និយោជក។

នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកអនុវត្តសេចក្តីជូនដំណឹង ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ត្រង់ចំណុចទី១ ដោយសងមកវិញនូវប្រាក់ថ្លៃទឹកដោះគោចំនួន ៣ ដុល្លារអាមេរិក ក្នុងកម្មករនិយោជិតម្នាក់ (កម្មករនិយោជិត ដែលធ្វើការទាមទារចំនួន ៣៥ នាក់) និងចំណុចទី២ សងមកវិញនូវប្រាក់ថ្លៃធ្វើដំណើរចំនួន ១០០០ រៀល ក្នុងកម្មករនិយោជិតម្នាក់ ដែលធ្វើការចាប់ពីម៉ោង ៧៖០០ ព្រឹក ដល់ម៉ោង ៦៖០០ ល្ងាច (កម្មករនិយោជិត ដែលធ្វើការទាមទារ ចំនួន ៥៦២ នាក់) ។ ពោលគឺសេចក្តីជូនដំណឹងនេះត្រូវមានអានុភាពអនុវត្ត តាំងពីខែកញ្ញា ឆ្នាំ២០១១ ប៉ុន្តែ ភាគីនិយោជកបានអនុវត្តចាប់ពីខែតុលា ឆ្នាំ២០១១។ ដោយភាគីកម្មករនិយោជិតបានទាមទារឱ្យនិយោជកអនុវត្តចំណុចទី៣ នៃកិច្ចព្រមព្រៀង ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាតែចំណុច

ទី១ និងទី២ថា តើនិយោជកចាំបាច់ត្រូវអនុវត្តតាមសេចក្តីជូនដំណឹងរបស់ខ្លួន ដោយសងទៅវិញនូវប្រាក់ថ្លៃទឹកដោះគោ និងប្រាក់ថ្លៃធ្វើដំណើរ ដែលមិនបានផ្តល់ជូនដល់កម្មករនិយោជិត នៅក្នុងខែកញ្ញា ឆ្នាំ២០១១ ដែរ ឬ ទេ?

មាត្រា ៦៥ នៃច្បាប់ស្តីពីការងារចែងថា *"កិច្ចសន្យាការងារ គឺ ជាកិច្ចសន្យា ដែលបង្កើតឱ្យមានការទាក់ទងផ្នែកការងាររវាងកម្មករនិយោជិត និងនិយោជក ។ កិច្ចសន្យានេះត្រូវនៅក្រោមវិធានអាជ្ញាគតិ ហើយអាចនឹងធ្វើទៅតាមទំរង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា "* ។

មាត្រា ៦៦៤ នៃក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឱ្យប្រើក្នុងឆ្នាំ២០០៧ ក៏បានកំណត់និយមន័យនៃកិច្ចសន្យាការងារផងដែរថា *" កិច្ចសន្យាការងារត្រូវបានបង្កើតឡើង ដោយការសន្យារបស់ភាគីម្ខាងថា ធ្វើពលកម្មឱ្យភាគីម្ខាងទៀត ហើយភាគីម្ខាងទៀតសន្យាថា ផ្តល់ប្រាក់ឈ្នួលទៅលើកិច្ចការពលកម្មនោះ "* ។

ជាក់ស្តែងមាត្រា៦៥ នៃច្បាប់ស្តីពីការងារកំណត់ថា កិច្ចសន្យាការងារស្ថិតនៅក្រោមវិធានទូទៅនៃការបង្កើតកិច្ចសន្យាផង ដែលវិធាននេះបច្ចុប្បន្ន ត្រូវស្ថិតនៅក្រោមក្រមរដ្ឋប្បវេណី ។

មាត្រា ៣០៩ - ប្រភពនៃកាតព្វកិច្ច នៃក្រមរដ្ឋប្បវេណី បានចែងថា ៖

*" ១- កាតព្វកិច្ចកើតមានឡើងដោយកិច្ចសន្យា ដោយសកម្មភាពឯកតោភាគី ដោយការគ្រប់គ្រងដោយឥតថ្នាល ដោយសេចក្តីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និងដោយបញ្ញត្តិច្បាប់ ។*

*២- កាតព្វកិច្ចដែលកើតឡើងដោយកិច្ចសន្យា និងដោយសកម្មភាពឯកតោភាគី គឺជាកាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី ..."* ។

តាមរយៈមាត្រា ៣០៩ នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីម្ខាងនៃកិច្ចសន្យាអាចបង្កើតនូវកាតព្វកិច្ចមួយដល់ខ្លួនឯង ដោយឯកតោភាគី ដែលខ្លួនត្រូវបំពេញទៅភាគីម្ខាងទៀត ។

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជកបានបង្កើតកាតព្វកិច្ចចំពោះខ្លួនគាត់ ដោយឯកតោភាគី តាមរយៈការចេញនូវសេចក្តីជូនដំណឹង ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ត្រង់ចំណុចទី១ (ផ្តល់ប្រាក់ថ្លៃទឹកដោះគោចំនួន ៣ ដុល្លារអាមេរិកបន្ថែមដល់កម្មករនិយោជិត) និងទី២ (ផ្តល់នូវប្រាក់ថ្លៃធ្វើដំណើរចំនួន ១០០០ រៀល ក្នុងកម្មករនិយោជិតម្នាក់ ដែលធ្វើការចាប់ពីម៉ោង ៧ ៖ ០០ ព្រឹក ដល់ម៉ោង ៦៖០០ ល្ងាច) ។

មាត្រា ៣២៩ - អត្ថន័យនៃការកំណត់ពេល នៃក្រមរដ្ឋប្បវេណី ត្រង់ចំណុចទី១ និង ទី៣ ចែងថា ៖

*" ១. ក្នុងករណីដែលមានកំណត់ពេលចាប់ផ្តើម ចំពោះអានុភាពនៃកិច្ចសន្យាអានុភាពនោះមិនត្រូវកើតឡើងរហូតដល់ពេលកំណត់នោះមកដល់ ... ។*

*២...*

*៣. ចំពោះសកម្មភាពឯកតោភាគី ភាគីអាចកំណត់ពេលចាប់ផ្តើម ក្នុងន័យនៃកថាខណ្ឌទី១ ឬ ពេលចប់ក្នុងន័យនៃកថាខ័ណ្ឌទី២ ខាងលើនេះបាន លុះត្រាតែមិននាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវដល់ភាគីម្ខាងទៀត "* ។

តាមមាត្រានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដែលបង្កើតសកម្មភាពជាឯកតោភាគីអាចកំណត់ពេលដែលសកម្មភាពនោះត្រូវមានអានុភាពអនុវត្ត ។

THE ARBITRATION COUNCIL

ក្នុងសំណុំរឿងនេះ ភាគីនិយោជកបានចេញសេចក្ដីជូនដំណឹងមួយ ដោយសន្យាថា នឹងផ្ដល់ប្រាក់ថ្លៃទឹកដោះគោ និងប្រាក់ថ្លៃធ្វើដំណើរមួយចំនួនដល់កម្មករនិយោជិត ដែលបានកំណត់ពេល មានអានុភាពអនុវត្តចាប់ពីខែកញ្ញា ឆ្នាំ២០១១។ តាមរយៈអង្គហេតុ ភាគីនិយោជកមិនបានផ្ដល់ជាថ្លៃទឹកដោះគោ និងប្រាក់ថ្លៃធ្វើដំណើរសម្រាប់ខែកញ្ញា ឆ្នាំ២០១១ ដូចការសន្យាទេ។ ភាគីនិយោជកបែរជាចាប់ផ្ដើមផ្ដល់ជូនចាប់ពីខែតុលា ឆ្នាំ២០១១ ទៅវិញ ដោយលើកហេតុផលនិយោជកមានខាតបង់ច្រើនដោយសារមានកូដកម្ម។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា សេចក្ដីជូនដំណឹងរបស់ក្រុមហ៊ុនមិនបានកំណត់លក្ខខណ្ឌនៅក្នុងការផ្ដល់ជូនអត្ថប្រយោជន៍ទាំងនោះ ជាឯកតោភាគី (ភាគីនិយោជក) ឬ លក្ខខណ្ឌ ដែលកម្មករនិយោជិតអាចទទួលបាននោះទេ។

តាមរយៈការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា និយោជកបានយល់ព្រមផ្ដល់នូវផលប្រយោជន៍មួយ ដែលមិនមានកំណត់លក្ខខណ្ឌក្នុងការផ្ដល់ជូនអត្ថប្រយោជន៍ទាំងនេះ និងបានកំណត់ពីកាលបរិច្ឆេទនៃអានុភាពអនុវត្តសេចក្ដីជូនដំណឹងនេះយ៉ាងជាក់លាក់។ លើសពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា មូលហេតុកូដកម្ម ដែលនិយោជកបានលើកឡើង ជាបញ្ហាដោយឡែកពីអ្វីដែលមានចែងនៅក្នុងសេចក្ដីជូនដំណឹងនេះ។ ភាគីនិយោជកមិនអាចយកបញ្ហាកូដកម្មនេះ ជាមូលហេតុនៅក្នុងការមិនបំពេញកាតព្វកិច្ចឯកតោភាគី ដែលមិនមានកំណត់លក្ខខណ្ឌរបស់ខ្លួននោះឡើយ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចបង្គាប់ឱ្យនិយោជកសងវិញនូវប្រាក់ថ្លៃទឹកដោះគោចំនួន៣ដុល្លារអាមេរិក ដល់កម្មការិនីចំនួន ៣៥ នាក់ និងប្រាក់ថ្លៃធ្វើដំណើរប្រចាំថ្ងៃ ចំនួន ១០០០ រៀល ជូនកម្មករនិយោជិតចំនួន ៥៦២ នាក់ ដែលធ្វើការចាប់ពីម៉ោង ៧៖០០ នាទីព្រឹក ដល់ម៉ោង ៦៖០០ ល្ងាច សម្រាប់ខែកញ្ញា ឆ្នាំ២០១១។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចចេញសេចក្ដីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**១- សេចក្ដីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ ៖**

**ចំណុចវិវាទទី១ និងទី២៨ ៖**

បង្គាប់ឱ្យនិយោជកសងវិញនូវប្រាក់ថ្លៃទឹកដោះគោចំនួន ៣ ដុល្លារអាមេរិក ចំពោះកម្មការិនីម្នាក់ៗ ដល់កម្មការិនីចំនួន ៣៥ នាក់ និងប្រាក់ថ្លៃធ្វើដំណើរប្រចាំថ្ងៃចំនួន ១០០០ រៀល ចំពោះកម្មករនិយោជិតម្នាក់ៗ ដល់កម្មករនិយោជិតចំនួន ៥៦២ នាក់ ដែលធ្វើការចាប់ពីម៉ោង ៧៖០០ នាទីព្រឹក ដល់ម៉ោង ៦៖០០ ល្ងាច សម្រាប់ខែកញ្ញា ឆ្នាំ២០១១។

**ប្រភេទនៃសេចក្ដីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ:**

*សេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសេចក្ដីសម្រេចផ្នែកទី១នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្ដង ដោយយោងតាមអនុស្សរណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១០។*

២- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ៖ គ្មាន

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ីុខ សុទ្ធី**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ឡួន ស៊ីផាន់**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ប៉ែន ប៊ុនឈា**

ហត្ថលេខា: ------------------------------